**Declassified to Public**
**12 June 2020**



**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**
**Royaume du Cambodge**
**Nation Religion Roi**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

---

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

**សំណុំរឿងលេខ៖ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស**

ចំពោះមុខ ៖ **សហចៅក្រមស៊ើបអង្កេត**

កាលបរិច្ឆេទ ៖ **ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១៦**

ភាសា ៖ **អង់គ្លេស [ភាសាដើម]**

ចំណាត់ថ្នាក់ឯកសារ ៖ **សម្ងាត់**

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 16-Aug-2016, 15:55
CMS/CFO: Sann Rada

---

# ដីកាសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំបន្តផ្តល់ធនធានចាំបាច់

---

**ផ្ញើជូន៖**

**សហព្រះរាជអាជ្ញា**

ជា លាង
Nicholas KOUMJIAN

**មេធាវីការពារក្តី អោ អាន**

មុំ លុជ្ស
Richard ROGERS
Göran SLUITER

**មេធាវីការពារក្តី យឹម ទិត្យ**

សូ មូស្សេន្នី
Suzana TOMANOVIĆ

**អង្គភាពគាំពារការការពារក្តី**

Isaac ENDELEY

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ជេត វណ្ណលី
ហុង គឹមសួន
គឹម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន ស៊ីវ៉ន
ទី ស្រ៊ីនណា
វ៉ែន ពៅ

Linda BEHNKE
Laure DESFORGES NZEPA
Herve DIAKIESE
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Beini YE

01318955



## I. ប្រវត្តិនីតិវិធី

១. ករណីខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត (“ស.ច.ស”) នៅក្នុងសំណុំរឿងនេះ បានចុះបញ្ជីនៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៣ និងថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥។

២. នៅថ្ងៃ ០៩ ខែ ឧសភា ឆ្នាំ ២០១៦ យោងតាមសំណើរបស់មេធាវីការពារក្តី អោ អាន (“មេធាវីការពារក្តី”)សុំបង្គាប់ឱ្យអង្គភាពគាំពារការការពារក្តី (“អ.គ.ក”)ផ្តល់ថវិកាសម្រាប់អ្នកប្រឹក្សាពីរនាក់បន្ថែមទៀត ខ្ញុំបានស្នើ អ.គ.ក ឱ្យសម្របសម្រួលតែងតាំងអ្នកប្រឹក្សាពីរនាក់ (“អ្នកប្រឹក្សាបន្ថែម”) រហូតដល់ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០១៦ ដោយអាចបន្តកិច្ចសន្យាការងារថែមទៀតប្រសិនបើតម្រូវការនៃកិច្ចស៊ើបសួរ ត្រូវតម្រូវឱ្យបន្តកិច្ចសន្យាការងារនេះ[1]។

៣. នៅថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ មេធាវីការពារក្តី បានជូនដំណឹង ស.ច.ស ថា ខ្លួនបានស្នើ អ.គ.ក សុំបន្តកិច្ចសន្យាការងាររបស់អ្នកប្រឹក្សាបន្ថែម រហូតថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៦។ នៅក្នុងសំណើរបស់ខ្លួន មេធាវីការពារក្តី បានបង្ហាញមូលហេតុដែលចាំបាច់ត្រូវបន្តកិច្ចសន្យាការងារទាំងនោះ។ នៅថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១៦ អ.គ.ក បានបដិសេធសំណើសុំបន្តកិច្ចសន្យាការងារ ដោយបញ្ជាក់ថា ខ្លួនមិនស្ថិតនៅក្នុងតួនាទីអាចសម្រេចថាតើតម្រូវការនៃកិច្ចស៊ើបសួរ ត្រូវតម្រូវឱ្យបន្តកិច្ចសន្យាការងារទាំងនោះដែរឬអត់នោះទេ។ បន្ទាប់ពីមានការបដិសេធបែបនេះ មេធាវីការពារក្តី បានស្នើ ស.ច.ស បង្គាប់ឱ្យ អ.គ.ក បន្តកិច្ចសន្យាការងាររបស់អ្នកប្រឹក្សាបន្ថែម រហូតដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៦ ដោយអាចបន្តកិច្ចសន្យាការងារថែមទៀតប្រសិនបើតម្រូវការនៃកិច្ចស៊ើបសួរ ត្រូវតម្រូវឱ្យបន្តកិច្ចសន្យាការងារនេះ[2]។

---

[1] សំណុំរឿង ០០៤ ឯកសារ D304/7 *ដីកាសម្រេចលើសំណើរបស់ អោ អាន សុំបង្គាប់ឱ្យអង្គភាពគាំពារការការពារក្តីផ្តល់ធនធានបន្ថែម* ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៦ កថាខណ្ឌ ៦។

[2] សំណុំរឿង ០០៤ ឯកសារ D304/10 *សំណើបន្ទាន់សុំបង្គាប់ឱ្យ អង្គភាពគាំពារការការពារក្តីបន្តផ្តល់ធនធានចាំបាច់* ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦។

## II. ពិភាក្សា

៤. សំណើសុំបន្តកិច្ចសន្យាការងាររបស់អ្នកប្រឹក្សាបន្ថែម គឺសមហេតុផល។ ការងាររបស់អ្នកប្រឹក្សាបន្ថែម នឹងត្រូវការជាចាំបាច់យ៉ាងហោចណាស់រហូតដល់ពេលចេញសេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរ យោងតាមវិធានផ្ទៃក្នុង ៦៦។ បន្ទាប់ពីកាលបរិច្ឆេទនោះ ចាំបាច់ត្រូវធ្វើការវាយតម្លៃឡើងវិញដោយផ្អែកលើការវិវត្តន៍នៃសំណុំរឿង និងការងាររបស់មេធាវីការពារក្តី នៅពេលនោះ។

៥. ដីកាសម្រេចនេះដាក់ជាភាសាអង់គ្លេសដោយឯកសារបកប្រែជាភាសាខ្មែរនឹងដាក់តាមក្រោយ។

**តាមសំអាងហេតុខាងលើ ខ្ញុំ ៖**

៦. **ជូនដំណឹង** អ.គ.ក ថា តម្រូវការនៃកិច្ចស៊ើបសួរ ផ្តល់យុត្តិកម្មឲ្យអនុញ្ញាតតាមសំណើសុំបន្តកិច្ចសន្យាការងារ រហូតដល់ពេលបិទកិច្ចស៊ើបសួរប្រឆាំង អោ អាន។

៧. **ស្នើ** អ.គ.ក បន្តកិច្ចសន្យាការងាររបស់អ្នកប្រឹក្សាបន្ថែម រហូតដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៦ ហើយបន្តកិច្ចសន្យាការងារបន្ថែមទៀតរហូតដល់ពេលបិទកិច្ចស៊ើបសួរ ប្រសិនបើកិច្ចស៊ើបសួរពន្យាររហួសថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៦។

ភ្នំពេញ ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១៦

**ចៅក្រម Michael Bohlander**

**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**

**International Co- Investigating Judge**

**Co-juge d’instruction International**